# មាតិកា


អារម្ភកថា
សេចក្ដីសម្រេចស្ដីពីគោលការណ៍ណែនាំសម្រាប់អនុវត្តការចូលរួមរបស់កុមារ.... ៣
ប្រការ ១ ៖ គោលបំណងនៃគោលការណ៍ណែនាំ ..........................៣
តើកុមារជាអ្នកណា? ................................................................. ៤
ប្រការ ២ ៖ និយមន័យនៃការចូលរួមរបស់កុមារ ............................ ៤
ប្រការ ៣ ៖ សារៈសំខាន់នៃការចូលរួមរបស់កុមារ ........................ ៤
ប្រការ ៤ ៖ កម្រិតនៃការចូលរួមរបស់កុមារ ................................... ៤
ប្រការ ៥ ៖ គោលការណ៍សំខាន់ៗនៃការចូលរួមរបស់កុមារ .......... ៥
គោលការណ៍ដោយស្ម័គ្រចិត្តរបស់កុមារ ........................ ៥
គោលការណ៍ផ្ដល់ព័ត៌មានគ្រប់គ្រាន់ដល់កុមារ ............. ៥
គោលការណ៍គោរពទស្សនៈរបស់កុមារ ......................... ៦
គោលការណ៍ឧត្តមប្រយោជន៍របស់កុមារ ..................... ៦
ការគាំទ្រពីមនុស្សពេញវ័យ ........................................... ៦
គោលការណ៍សុវត្ថិភាពសម្រាប់កុមារ .......................... ៦
គោលការណ៍ការរួមបញ្ចូល និងការមិនរើសអើង .......... ៦
ប្រការ ៦ ៖ នៅពេលណាត្រូវឱ្យកុមារចូលរួម ................................៧
តើត្រូវឱ្យកុមារចូលរួមយ៉ាងដូចម្ដេច .............................៧
ដំណាក់កាលមុនព្រឹត្តិការណ៍ ........................................៧
ជំហានទី ១៖ គោលបំណងដ៏ច្បាស់លាស់ ....................៧
ជំហានទី ២៖ ការចែករំលែកព័ត៌មាន .............................៧
ជំហានទី ៣៖ ការជ្រើសរើសតំណាងរបស់កុមារ ............ ៨
ហានទី ៤៖ ទីកន្លែង ...................................................... ៨
ជំហានទី ៥៖ ភាសា និងលំហូរនៃការពិភាក្សា ................ ៨
ជំហានទី ៦៖ ក្រុមគាំទ្រ ................................................ ៨
ជំហានទី ៧៖ ការយល់ព្រម និងការវាយតម្លៃហានិភ័យ . ៩

ជំហានទី ៨៖ ការធ្វើដំណើរ និងការស្នាក់នៅ ................. ៩
ជំហានទី ៩៖ អ្នកមើលថែទាំកុមារ .................................. ៩
ជំហានទី ១០៖ ការស្លៀកសម្លៀកបំពាក់សមស្រប ........ ៩
ដំណាក់កាលក្នុងអំឡុងព្រឹត្តិការណ៍ ............................... ៩
ជំហានទី ១៖ ការរៀបចំកន្លែងអង្គុយ ...........................១០
ជំហានទី ២៖ ការសម្របសម្រួលការពិភាក្សា .........................១០
ជំហានទី ៣៖ ឱកាសស្មើគ្នា ..................................................១០
ជំហានទី ៤៖ ការផ្តល់យោបល់ជាវិជ្ជមានត្រឡប់ទៅវិញ .........១០
ជំហានទី ៥៖ ការគោរពគ្នាទៅវិញទៅមក .............................១១
ជំហានទី ៦៖ ភាសា ..............................................................១១
ជំហានទី ៧៖ ការគាំទ្រ ..........................................................១១
ដំណាក់កាលក្រោយព្រឹត្តិការណ៍ ..........................................១១
ការរៀបចំបញ្ជីសម្រាប់ផ្ទៀងផ្ទាត់ ............................................១១
ប្រការ ៧ ៖ ការទុកជានិរាករណ៍ ................................................ ១២
ប្រការ ៨ ៖ ក្រសួង ស្ថាប័ន ដែលជាសមាជិក ......................................... ១២
ឧបសម្ព័ន្ធទី ១៖ ទម្រង់នៃការព្រមព្រៀងសម្រាប់កុមារ ...........១៣
ឧបសម្ព័ន្ធទី ២៖ ទម្រង់នៃការវាយតម្លៃ និងការកាត់បន្ថយហានិភ័យ ..............................................................................១៤
ឧបសម្ព័ន្ធទី ៣៖ ទម្រង់នៃការព្រមព្រៀងរបស់ឪពុកម្តាយ ......១៥
ឧបសម្ព័ន្ធទី ៤៖ តួនាទីរបស់អ្នកមើលថែទាំកុមារ ...................១៦
ឧបសម្ព័ន្ធទី ៥៖ មាត្រាដែលពាក់ព័ន្ធនឹងការចូលរួមរបស់កុមារ ..១៨
ឧបសម្ព័ន្ធទី ៦៖ វិធីសាស្រ្ត ......................................................១៩
ឯកសារយោង...................................................................... ២០

# អារម្ភកថា

ដើម្បីជាឧត្តមប្រយោជន៍របស់កុមារ កម្ពុជាបានផ្តល់សច្ចាប័នលើអនុសញ្ញាអន្តរជាតិស្តីពីសិទ្ធិកុមារ នៅថ្ងៃទី១៥ ខែតុលា ឆ្នាំ១៩៩២ ហើយរដ្ឋធម្មនុញ្ញនៃព្រះរាជាណាចក្រកម្ពុជាឆ្នាំ១៩៩៣ បានចែងថា រដ្ឋធានារក្សាការពារសិទ្ធិរបស់កុមារដូចមានចែងក្នុងអនុសញ្ញាស្តីពីសិទ្ធិកុមារនេះជាពិសេសសិទ្ធិមានជីវិតរស់នៅ សិទ្ធិទទួលបានការអប់រំរៀនសូត្រ សិទ្ធិត្រូវបានទទួលការគាំពារក្នុងស្ថានការណ៍មានសង្គ្រាម និងការការពារប្រឆាំងនឹងអាជីវកម្មសេដ្ឋកិច្ច ឬកាមគុណលើកុមារ។ រដ្ឋគាំពារប្រឆាំងនឹងការងារទាំងឡាយដែលអាចធ្វើឱ្យខូចដល់ការអប់រំ និងការរៀនសូត្ររបស់កុមារ ឬដែលនាំឱ្យអន្តរាយដល់សុខភាព ឬសុខុមាលភាពរបស់កុមារ។ ដើម្បីជាឧត្តមប្រយោជន៍របស់កុមារផងដែរ កម្ពុជាបានផ្តល់សច្ចាប័នលើអនុសញ្ញាអន្តរជាតិមួយចំនួនទៀតជាបន្តបន្ទាប់ ដូចជា អនុសញ្ញារបស់អង្គការពលកម្មអន្តរជាតិលេខ១៣៨ ស្តីពីអាយុអប្បបរមាសម្រាប់ចូលធ្វើការ អនុសញ្ញាលេខ១៨២ ស្តីពីការហាមប្រាម និងសកម្មភាពបន្ទាន់សម្រាប់ការលុបបំបាត់ទម្រង់ធ្ងន់ធ្ងរបំផុតនៃពលកម្មកុមារ ពិធីសារបន្ថែមចំនួនពីរនៃអនុសញ្ញាស្តីពីសិទ្ធិកុមារអំពីការចូលរួមរបស់កុមារនៅក្នុងជម្លោះប្រដាប់អាវុធ និងអំពីការជួញដូរកុមារ ការធ្វើពេស្យាកម្មកុមារ និងរូបភាពអាសអាភាសកុមារ ពិធីសារស្តីពីការទប់ស្កាត់ ការបង្ក្រាប និងការដាក់ទណ្ឌកម្មការជួញដូរមនុស្សពិសេសស្ត្រី និងកុមារ និងអនុសញ្ញាក្រុងឡាអេស្តីពីកិច្ចការពារកុមារ និងសហប្រតិបត្តិការទាក់ទងនឹងសុំកូនអន្តរប្រទេស។

ក្រោមការដឹកនាំប្រកបដោយគតិបណ្ឌិតរបស់**សម្តេចអគ្គមហាសេនាបតីតេជោ ហ៊ុន សែន នាយករដ្ឋមន្ត្រីនៃព្រះរាជាណាចក្រកម្ពុជា** បានធ្វើឱ្យប្រទេសកម្ពុជាទទួលបាននូវការរីកចម្រើនលើគ្រប់វិស័យ ក្នុងនោះវិស័យសុខុមាលភាពកុមារមានការរីកចម្រើនគួរឱ្យកត់សម្គាល់ ដោយបានកំណត់ការងារ កុមារជាអាទិភាពនៅក្នុងកម្មវិធីនយោបាយរបស់ខ្លួន។ នៅក្នុងឱកាស

ទិវាកុមារ អន្តរជាតិ១មិថុនាលើកទី៦៤ និងទិវាប្រឆាំងពលកម្មកុមារ១២ មិថុនា និងទិវាកុមារកម្ពុជាឆ្នាំ២០១៣ **សម្តេចអគ្គមហាសេនាបតីតេជោ ហ៊ុន សែន នាយករដ្ឋមន្ត្រីនៃព្រះរាជាណាចក្រកម្ពុជា** បានផ្តល់នូវ អនុសាសន៍ដ៏ខ្ពង់ខ្ពស់ "ដើម្បីផ្តល់នូវឱកាសដល់កុមារក្នុងការអនុវត្តសិទ្ធិរបស់ពួកគេក្នុងការចូលរួមក្នុងវេទិកានៅគ្រប់កម្រិតទាំងមូលដ្ឋាន ថ្នាក់ជាតិនិងតំបន់។រាល់មតិយោបល់របស់កុមារត្រូវបានយកមកពិចារណា និងដាក់បញ្ចូលទៅក្នុងផែនការសកម្មភាពនានាសម្រាប់អភិវឌ្ឍសិទ្ធិកុមារ។ ការជំរុញឱ្យកុមារចូលរួមគឺ យើងអាចដោះស្រាយបញ្ហារបស់ពួកគេកាន់តែមានប្រសិទ្ធភាពខ្ពស់។ នៅក្នុងអត្ថន័យនេះ ប្រសិនបើមានការរំលោភបំពានសិទ្ធិកុមារដូចជាការបោះបង់ចោលការសិក្សា ឬការកេងប្រវ័ញ្ចកុមារ ការរាយការណ៍ពីបញ្ហានេះកាន់តែលឿនពីកុមារដល់អាជ្ញាធរក្នុងការឆ្លើយតបទាន់ពេលវេលា និងមានប្រសិទ្ធភាព។ ជាមួយគ្នាផងដែរ ក្រសួងកិច្ចការនារីកំពុងសហការ ជាមួយដៃគូរអភិវឌ្ឍន៍ដើម្បីពន្លឿនការសិក្សាស្រាវជ្រាវ និងវាយតម្លៃពីការរំលោភបំពានកុមារ ក្នុងការឆ្លើយតបឱ្យមានប្រសិទ្ធភាព។"

យោងតាមខ្លឹមសារនៃអនុសញ្ញាស្តីពីសិទ្ធិកុមារ ជាពិសេសមាត្រា ១២ ១៣ ១៥ ១៧ និង ៤២ បានលើកឡើងអំពីតួនាទីយ៉ាងសំខាន់របស់រដ្ឋជាភាគី ដែលត្រូវធានាចំពោះកុមារនូវឱកាស ក្នុងការសម្តែងមតិ និងទទួលបានព័ត៌មាន និងសិទ្ធិជួបជុំដោយសន្តិវិធី។ ការលើកកម្ពស់ការចូលរួមរបស់កុមារ គឺផ្តល់ឱកាសឱ្យកុមារបានចូលរួមធ្វើគោលការណ៍សម្រេចចិត្ត ដើម្បីឆ្លើយតបទៅនឹងតម្រូវការជាក់ស្តែងលើបញ្ហាដែលពាក់ព័ន្ធនឹងកុមារ ព្រោះមានតែកុមារទេដែលដឹងពីស្ថានភាព របស់ខ្លួនគេច្បាស់លាស់ជាងអ្នកដទៃ។ ហេតុនេះហើយបានជាក្រសួង ស្ថាប័ន ដៃគូអភិវឌ្ឍន៍ និងអង្គការមិនមែនរដ្ឋាភិបាលជាតិ និងអន្តរជាតិ ចូលរួមបង្កើតឱ្យមានក្លឹបចលនាយុវជន ឬកុមារជាច្រើនទៀតដូចជា ចលនាយុវជនកាកបាទក្រហមកម្ពុជា និងកាយរិទ្ធិកម្ពុជា ក្លឹបកុមារនៅតាមសាលារៀន បណ្តាញកុមារតស៊ូមតិ ចលនាកុមារនិងយុវជន

កម្ពុជាដើម្បីសិទ្ធិកុមារ ដែលពួកគេ ក្លាយជាចលនាយុវជន ឬកុមារឈានមុខនៅក្នុងសង្គម និងបានចូលរួមវេទិកាថ្នាក់មូលដ្ឋាន ថ្នាក់ជាតិ ថ្នាក់តំបន់ និងអន្តរជាតិ។

សេចក្តីសម្រេចស្តីពីគោលការណ៍ណែនាំ សម្រាប់អនុវត្តការចូលរួមរបស់កុមារជាជំហានថ្មី នៃការបង្កើនប្រសិទ្ធភាពនៃការចូលរួមរបស់កុមារក្នុងការអនុវត្តសិទ្ធិកុមារ។ ក្រុមប្រឹក្សាជាតិកម្ពុជាដើម្បីកុមារមានជំនឿយ៉ាងមុតមាំថា សេចក្តីសម្រេចនេះជាឧបករណ៍មួយសម្រាប់ ក្រសួង ស្ថាប័ន អាជ្ញាធរមូលដ្ឋានពាក់ព័ន្ធគ្រប់លំដាប់ថ្នាក់ និងអង្គការពាក់ព័ន្ធទាំងឡាយប្រើប្រាស់ជាប្រយោជន៍ ប្រកបដោយប្រសិទ្ធភាពសម្រាប់ជំរុញការចូលរួមរបស់កុមារក្នុងការបញ្ចេញមតិ និងការព្រួយបារម្ភ នៅក្នុងការងារដែលពាក់ព័ន្ធនឹងពួកគេ និងជំរុញការអនុវត្តសិទ្ធិចូលរួមរបស់កុមារនេះកាន់តែប្រសើរឡើង។

ក្រុមប្រឹក្សាជាតិកម្ពុជាដើម្បីកុមារសូមថ្លែងអំណរគុណចំពោះក្រុមការងារអគ្គលេខាធិការដ្ឋានក្រុមប្រឹក្សាជាតិកម្ពុជាដើម្បីកុមារ អង្គការភ្លែនអន្តរជាតិកម្ពុជា អង្គការ Save the Children និង សម្ពន្ធអង្គការមិនមែនរដ្ឋាភិបាលដើម្បីសិទ្ធិកុមារ ដែលបានផ្តល់ការគាំទ្រផ្នែកហិរញ្ញវត្ថុ និងបច្ចេកទេសដល់ការរៀបចំឯកសារដ៏មានសារៈសំខាន់ ហើយសង្ឃឹមថាសេចក្តីសម្រេចនេះនឹងត្រូវបានអនុវត្តប្រកបដោយប្រសិទ្ធភាពខ្ពស់ក្នុងការលើកកម្ពស់សិទ្ធិចូលរួមដើម្បីជាឧត្តមប្រយោជន៍របស់កុមារគ្រប់ៗរូប។

រាជធានីភ្នំពេញ, ថ្ងៃទី ២៤ ខែ កុម្ភៈ ឆ្នាំ២០១៤

**ប្រធានក្រុមប្រឹក្សាជាតិកម្ពុជាដើម្បីកុមារ**

**វង សូត**

**ព្រះរាជាណាចក្រកម្ពុជា**
**ជាតិ សាសនា ព្រះមហាក្សត្រ**

**ក្រុមប្រឹក្សាជាតិកម្ពុជាដើម្បីកុមារ**

លេខ:០១៨ ក.ជ.ក.

រាជធានីភ្នំពេញ, ថ្ងៃទី២៤ ខែកុម្ភៈ ឆ្នាំ ២០១៤

# សេចក្តីសម្រេច
# ស្តីពី
# គោលការណ៍ណែនាំសម្រាប់អនុវត្តការចូលរួមរបស់កុមារ
# ប្រធានក្រុមប្រឹក្សាជាតិកម្ពុជាដើម្បីកុមារ

- បានឃើញរដ្ឋធម្មនុញ្ញនៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រឹត្យលេខ នស/រកត/០៩១៣/៩០៣ ចុះថ្ងៃទី ២៤ ខែកញ្ញា ឆ្នាំ២០១៣ ស្តីពីការតែងតាំងរាជរដ្ឋាភិបាលនៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រមលេខ ០២/នស/៩៤ ចុះថ្ងៃទី ២០ ខែ កក្កដា ឆ្នាំ ១៩៩៤ ដែលប្រកាស ឱ្យប្រើច្បាប់ស្តីពីការរៀបចំ និងការប្រព្រឹត្តទៅនៃគណៈរដ្ឋមន្ត្រី
- បានឃើញព្រះរាជក្រឹត្យលេខ នស/រកត/១២០៩/១២០១ ចុះថ្ងៃទី ២១ ខែ ធ្នូ ឆ្នាំ ២០០៩ ស្តីពីការបង្កើតក្រុមប្រឹក្សាជាតិកម្ពុជាដើម្បីកុមារ
- យោងតាមអនុសញ្ញាស្តីពីសិទ្ធិកុមារ ដែលក្រុមប្រឹក្សាជាតិជាន់ខ្ពស់បានចុះហត្ថលេខានៅថ្ងៃទី២២ ខែកញ្ញា ឆ្នាំ១៩៩២ និងត្រូវបានផ្តល់សច្ចាប័ន នៅថ្ងៃទី១៥ ខែតុលា ឆ្នាំ១៩៩២
- យោងតាមពិធីសារបន្ថែម នៃអនុសញ្ញាស្តីពីការចូលរួមរបស់កុមារ

នៅក្នុងជម្លោះប្រដាប់អាវុធ និងពិធីសារបន្ថែមស្តីពីការជួញដូរកុមារ ការធ្វើពេស្យាកម្មកុមារ និងរូបភាពអាសអាភាសកុមារ ដែលរដ្ឋសភាបានផ្តល់សច្ចាប័ននៅថ្ងៃទី ០២ ខែ មករា ឆ្នាំ ២០០២

- យោងតាមសារាចរណែនាំរបស់រាជរដ្ឋាភិបាល ស្តីពីការអនុវត្តអនុសាសន៍របស់គណៈកម្មាធិការសិទ្ធិកុមារនៃអង្គការសហប្រជាជាតិ ចុះថ្ងៃទី ១៣ ខែ កក្កដា ឆ្នាំ ២០១២

## សម្រេច

**ប្រការ ១.-**

### គោលបំណងនៃគោលការណ៍ណែនាំ

គោលការណ៍ណែនាំនេះបង្កើតឡើងដើម្បីជួយមនុស្សពេញវ័យដែលធ្វើការងារពាក់ព័ន្ធនឹងកុមារនៅគ្រប់ស្ថាប័នរួមមាន រាជរដ្ឋាភិបាល អង្គការមិនមែនរដ្ឋាភិបាល អង្គការអន្តរជាតិ និងសហគមន៍ ក្នុងគោលបំណងលើកកម្ពស់ការចូលរួមរបស់កុមារប្រកបដោយគុណភាពនៅថ្នាក់អន្តរជាតិ ថ្នាក់ជាតិ និងថ្នាក់ក្រោមជាតិ។

គោលការណ៍ណែនាំផ្តល់នូវគន្លឹះ និងជំហាន ដើម្បីធ្វើការសម្របសម្រួលការចូលរួមរបស់កុមារបានបញ្ចេញនូវទស្សនៈរបស់ខ្លួនបានល្អនៅក្នុងកិច្ចប្រជុំសិក្ខាសាលាពិគ្រោះយោបល់ ឬនៅក្នុងដំណើរការនៃការធ្វើសេចក្តីសម្រេចផ្សេងៗ។ គោលការណ៍ណែនាំនេះនឹងណែនាំអ្នកប្រើប្រាស់ឱ្យចេះបែងចែកការសម្របសម្រួលជា ៣ ដំណាក់កាល រួមមានដំណាក់កាលមុនព្រឹត្តិការណ៍ដំណាក់កាលក្នុងព្រឹត្តិការណ៍ និងដំណាក់កាលក្រោយព្រឹត្តិការណ៍ដែលកុមារចូលរួម។

**តើកុមារជាអ្នកណា?**

យោងតាមក្រមរដ្ឋប្បវេណីកម្ពុជាឆ្នាំ ២០០៧ និងអនុសញ្ញាស្តីពីសិទ្ធិកុមារ កុមារគឺជាមនុស្សគ្រប់រូប ដែលមានអាយុក្រោម ១៨ឆ្នាំ។

## ប្រការ ២.~

### និយមន័យនៃការចូលរួមរបស់កុមារ

ការចូលរួមរបស់កុមារ ត្រូវបានផ្តល់និយមន័យទៅតាមបរិបទខុសៗគ្នានៃក្រុមមនុស្សដែលធ្វើការងារពាក់ព័ន្ធនឹងកុមារ។ នៅក្នុងបរិបទនៃគោល-ការណ៍ណែនាំនេះការចូលរួមរបស់កុមារសំដៅលើការផ្តល់ឱកាសដល់កុមារក្នុងការចែករំលែកទស្សនៈរបស់ពួកគេ នៅក្នុងដំណើរការនៃការធ្វើសេចក្តីសម្រេចផ្សេងៗលើបញ្ហាទាំងឡាយដែលធ្វើឱ្យប៉ះពាល់ដល់ពួកគេ។

*(សូមអានមាត្រាដែលពាក់ព័ន្ធស្តីពីការចូលរួមរបស់កុមារនៅក្នុងឧបសម្ព័ន្ធទី ៥)*

## ប្រការ ៣.~

### សារៈសំខាន់នៃការចូលរួមរបស់កុមារ

ការចូលរួមរបស់កុមារ គឺជាដំណើរការរៀនសូត្រមួយសម្រាប់កុមារក្នុងការអភិវឌ្ឍ និងរៀបចំខ្លួនរបស់ពួកគេមុនក្លាយជាមនុស្សពេញវ័យ និងក្លាយជាប្រជាពលរដ្ឋដ៏សកម្មមានសមត្ថភាព និងចេះប្រាស្រ័យទាក់ទងក្នុងសង្គម។ ការចូលរួមរបស់កុមារជាមធ្យោបាយធ្វើឱ្យកុមារទទួលបានសិទ្ធិផ្សេងៗទៀតដែលមានចែងនៅក្នុងអនុសញ្ញាស្តីពីសិទ្ធិកុមារ។ ការចូលរួមរបស់កុមារធ្វើឱ្យអ្នក ដែលធ្វើការងារពាក់ព័ន្ធនឹងកុមារមានការយល់ដឹងកាន់តែប្រសើរអំពីតម្រូវការ និងផលប្រយោជន៍ របស់កុមារដើម្បីឆ្លើយតបឱ្យបានកាន់តែល្អប្រសើរ។ កុមារបានដឹងអំពីជីវិតរបស់ពួកគេ ហើយពួក គេមានគំនិតអារម្មណ៍និងទស្សនៈផ្ទាល់ខ្លួនរបស់ពួកគេ។ ការចូលរួមរបស់កុមារ គឺជាវិធីសាស្ត្រមួយក្នុងការកសាងនូវការគោរពខ្លួនឯង និងអ្នកដទៃ ទំនុកចិត្តមកលើខ្លួនឯងនិងភាពជាអ្នកដឹកនាំសម្រាប់កុមារ។

**ប្រការ ៤.~**

## កម្រិតនៃការចូលរួមរបស់កុមារ

ការចូលរួមរបស់កុមារមានច្រើនកម្រិត។ការចូលរួមរបស់កុមារនៅក្នុងគោលការណ៍ណែនាំ នេះផ្តោតទៅលើការចូលរួមរបស់កុមារតែ២កម្រិតប៉ុណ្ណោះ រួមមាន៖ កម្រិតទី១គឺ ការពិគ្រោះយោបល់ជាមួយកុមារ និងកម្រិតទី២គឺ មនុស្សពេញវ័យសហការជាមួយកុមារក្នុងការធ្វើសេចក្តីសម្រេចរួមគ្នា។

**កម្រិតទី១ ពិគ្រោះយោបល់ជាមួយកុមារ ៖** មានន័យថា មនុស្សពេញវ័យពិភាក្សាជាមួយកុមារ ដើម្បីស្វែងរកទស្សនៈកុមារពាក់ព័ន្ធនឹងជីវិត និងបទពិសោធន៍របស់កុមារ។ នៅក្នុងកម្រិតនេះ មនុស្សធំមានគំនិតផ្តួចផ្តើមរួចហើយ និងបានដឹកនាំចាត់ចែងនៅក្នុងដំណើរការពិគ្រោះយោបល់បន្ទាប់មក មនុស្សធំត្រូវស្តាប់ និងទទួលយកទស្សនៈរបស់កុមារមកដាក់ជារបៀបវារៈ និងផែនការសកម្មភាពរបស់ខ្លួន។

**កម្រិតទី២ ការធ្វើសេចក្តីសម្រេចរួមគ្នា ៖** មានន័យថា មនុស្សពេញវ័យមានគំនិតផ្តួចផ្តើម ឬកុមារមាន គំនិតផ្តួចផ្តើម ក៏ប៉ុន្តែមនុស្សពេញវ័យ និងកុមារត្រូវពិភាក្សានូវគំនិតផ្តួចផ្តើមទាំងនោះជាមួយគ្នា និងធ្វើសេចក្តីសម្រេចរួមគ្នាក្នុងភាពជាដៃគូដោយគិតពីឧត្តមប្រយោជន៍របស់កុមារ និងមានការគោរពគ្នាទៅវិញទៅមក។ កុមារ និង មនុស្សពេញវ័យឯកភាពគ្នាលើតួនាទី និងការទទួលខុសត្រូវរួមគ្នាក្នុងការអនុវត្ត និងចាត់ចែងនូវគំនិតផ្តួចផ្តើមទាំងនោះ។ កុមារ និងមនុស្សពេញវ័យដែលចូលរួមនៅក្នុងការពិភាក្សាគំនិតផ្តួចផ្តើមទាំងនោះ គឺជាម្ចាស់លើលទ្ធផលនៃគំនិតផ្តួចផ្តើមទាំងនោះ។

**ប្រការ ៥.-**

គោលការណ៍សំខាន់ៗការចូលរួមរបស់កុមារ ដែលត្រូវអនុវត្តនៅពេលធ្វើការជាមួយកុមារនៅគ្រប់សកម្មភាពមានដូចខាងក្រោម៖

**គោលការណ៍ដោយស្ម័គ្រចិត្តរបស់កុមារ**

ការចូលរួមរបស់កុមារ ត្រូវតែជាការចូលរួមតាមការស្ម័គ្រចិត្ត និងមិនមានការបង្ខិតបង្ខំទៅលើកុមារណាម្នាក់ឡើយ។ កុមារអាចជ្រើសរើសដោយសេរីដើម្បីចូលរួម ឬមិនចូលរួមនៅក្នុងដំណើរការចូលរួមនេះ ព្រមទាំងមានឱកាសដកខ្លួនពីសកម្មភាពបានគ្រប់ពេលវេលាបើពួកគេចង់ដោយមានការផ្តល់ព័ត៌មានជាមុនដល់អ្នកសម្របសម្រួល។ ការចូលរួមរបស់កុមារមិនគួរធ្វើឱ្យប៉ះពាល់ធ្ងន់ធ្ងរទៅលើការងារដទៃទៀតរបស់កុមារឡើយ ដូចជាពេលវេលាសិក្សា សកម្មភាពនៅផ្ទះ ពេលវេលាលេងកម្សាន្ត ។ល។

**គោលការណ៍ផ្តល់ព័ត៌មានគ្រប់គ្រាន់ដល់កុមារ**

កុមារគួរទទួលបាននូវព័ត៌មានដ៏ពេញលេញ និងងាយយល់អំពីប្រវត្តិគោលបំណង និងលទ្ធផលដែលអាចកើតឡើងនៃព្រឹត្តិការណ៍នានាដែលខ្លួនចូលរួម នៅក្នុងដំណើរការនៃការធ្វើសេចក្តីសម្រេចថាខ្លួននឹងចូលរួម ឬមិនចូលរួម។ ព័ត៌មាននេះរួមមានហានិភ័យ ដែលអាចកើតមានឡើងនៅក្នុងដំណើរការ ដូចជាគ្រោះថ្នាក់ពេលធ្វើដំណើរ។ល។ ក្រោយពីព្រឹត្តិការណ៍បានបញ្ចប់គេគួរតែប្រាប់កុមារអំពីលទ្ធផលនៃព្រឹត្តិការណ៍នោះឱ្យកុមារបានដឹងផង។

**គោលការណ៍គោរពទស្សនៈរបស់កុមារ**

ការចូលរួមរបស់កុមារគួរមានការរៀបចំ ឬមានដំណើរការសម្រាប់ឱ្យកុមារបញ្ចេញនូវទស្សនៈផ្ទាល់ខ្លួនរបស់ពួកគេដោយសេរី នៅក្នុងការពិភាក្សាលើបញ្ហានានាពាក់ព័ន្ធនឹងជីវិតរបស់កុមារ ហើយពួកគេត្រូវមានការគោរពចំពោះគំនិតរបស់ពួកគេផងដែរ។ មនុស្សពេញវ័យក៏អាចលើកនូវគំនិតរបស់

ខ្លួនមកពិភាក្សាជាមួយកុមារក្នុងករណីចាំបាច់ ហើយកុមារជាអ្នកផ្តល់មតិត្រឡប់ និងយល់ព្រម។

## គោលការណ៍ឧត្តមប្រយោជន៍របស់កុមារ

លទ្ធផលនៃការចូលរួមរបស់កុមារ ត្រូវបម្រើឧត្តមប្រយោជន៍របស់កុមារដោយផ្ទាល់ឬដោយប្រយោលទាំងឧត្តមប្រយោជន៍រយៈពេលខ្លីនិងឧត្តមប្រយោជន៍រយៈពេលវែង។ ប្រសិនបើ មិនអាចធ្វើបានទេនោះ គេមិនគួរឱ្យកុមារចូលរួមនៅក្នុងដំណើរការនោះទេ។

ដំណើរការនៃការចូលរួមរបស់កុមារ មិនគួរធ្វើឱ្យខូចប្រយោជន៍ដល់ការអប់រំ សកម្មភាពកម្សាន្តជាមួយមិត្តភក្តិ និងការងារសម្រាប់គ្រួសាររបស់កុមារ និងដាក់បន្ទុកបន្ថែមដល់កុមារឡើយ។

## ការគាំទ្រពីមនុស្សពេញវ័យ

មនុស្សពេញវ័យត្រូវផ្តល់នូវការគាំទ្ររបស់ខ្លួនគ្រប់ពេលវេលាទាំងអស់ដល់ការចូលរួមរបស់កុមារទាំងមុនព្រឹត្តិការណ៍ ក្នុងអំឡុងពេលព្រឹត្តិការណ៍ និងក្រោយព្រឹត្តិការណ៍។មនុស្សពេញវ័យគួរធ្វើឱ្យប្រាកដថាកុមារទទួលបាននូវព័ត៌មានដែលពាក់ព័ន្ធទាំងអស់អំពីប្រធានបទនានានៃការពិភាក្សា។ មនុស្សពេញវ័យគួរធ្វើឱ្យប្រាកដថា កុមារមានការយល់ដឹងពេញលេញនូវព័ត៌មានបែបនោះ។ មនុស្សពេញវ័យគួរធ្វើឱ្យប្រាកដថា កុមារមានការយល់ដឹងអំពីដំណើរការនៃការពិភាក្សា ដើម្បីឱ្យកុមារអាចបញ្ចេញនូវគំនិតរបស់ខ្លួន ដោយការជឿទុកចិត្ត និងប្រកបដោយអត្ថន័យ និងចំពេលវេលា។ ឯកសារសម្រាប់អាន និងភាសានិយាយគួរធ្វើឱ្យមានលក្ខណៈងាយស្រួលយល់សម្រាប់កុមារ ហើយបរិយាកាសពិភាក្សាគួរមានលក្ខណៈស្និទ្ធស្នាលគ្មានគំនាប និងមិនបង្ហាញនូវការធ្វើឱ្យកុមារភ័យខ្លាចឡើយ។

### គោលការណ៍សុវត្ថិភាពសម្រាប់កុមារ

កុមារគួរត្រូវបានការពារ ហើយសន្តិសុខរបស់ពួកគេត្រូវបានធានាទាំងមុនពេលក្នុងអំឡុងពេល និងក្រោយពេលនៃព្រឹត្តិការណ៍។ ត្រូវមានការវាយតម្លៃអំពីហានិភ័យ ដើម្បីមានវិធានការទប់ស្កាត់ ក្នុងការធានាសុវត្ថិភាពដល់កុមារ។

### គោលការណ៍ការរួមបញ្ចូល និងការមិនរើសអើងចំពោះកុមារ

នៅពេលធ្វើការប្រមូលទស្សនៈរបស់កុមារ ត្រូវប្រាកដថាទស្សនៈរបស់កុមារគ្រប់ប្រភេទ ដូចជាទស្សនៈរបស់កុមារា ឬទាំងទស្សនៈរបស់កុមារី កុមារមិនចូលសាលារៀន កុមារកំពុងធ្វើការ កុមារពិការ កុមារមានផ្ទុកមេរោគអេដស៍ កុមារក្រុមជនជាតិភាគតិច កុមារនៅតំបន់ដាច់ស្រយាល កុមាររស់នៅក្នុងមណ្ឌលថែទាំ និងមណ្ឌលកែប្រែត្រូវបានបញ្ចូល។ល។

## ប្រការ ៦.-

### ពេលវេលាដែលត្រូវឲ្យកុមារចូលរួម

កុមារត្រូវការពេលវេលាច្រើនដើម្បីធ្វើការអភិវឌ្ឍនូវបុគ្គលិកលក្ខណៈរបស់ខ្លួនដើម្បីក្លាយជាប្រជាពលរដ្ឋដែលមានសមត្ថភាព និងមានប្រសិទ្ធភាព។ ដូច្នេះ គេគួរឱ្យកុមារចូលរួមនៅក្នុងការពិភាក្សា ឬការពិគ្រោះយោបល់ណា ដែលសេចក្តីសម្រេចផ្សេងៗធ្វើឱ្យប៉ះពាល់ដល់កុមារ និងជីវិតរបស់កុមារ។ ប្រសិនបើមិនប៉ះពាល់ដល់ផលប្រយោជន៍កុមារទេនោះ កុមារមិនគួរត្រូវបានរំខានឡើយ។

### តើត្រូវឱ្យកុមារចូលរួមយ៉ាងដូចម្តេច?

ដើម្បីជួយកុមារឱ្យបានបញ្ចេញនូវគំនិត ឬមតិយោបល់របស់ខ្លួនទៅលើបញ្ហានានា ដែលពាក់ព័ន្ធជាមួយពួកគេ អ្នកប្រតិបត្តិទាំងអស់ត្រូវតែអនុវត្តតាមគោលការណ៍សំខាន់ៗខាងលើ។ អ្នកប្រតិបត្តិគួររៀបចំការចូលរួមរបស់កុមារជា ៣ ដំណាក់កាលផ្សេងៗគ្នា គឺដំណាក់កាលមុនព្រឹត្តិការណ៍ក្នុងអំឡុងព្រឹត្តិការណ៍ និងក្រោយព្រឹត្តិការណ៍ (ព្រឹត្តិការណ៍រួមមានវេទិកាសន្និសីទ

សិក្ខាសាលាកិច្ចប្រជុំ ការបណ្តុះបណ្តាលកិច្ចពិភាក្សា។ល។) ដែលកុមារចូលរួម ដូចខាងក្រោម៖

**ដំណាក់កាលមុនព្រឹត្តិការណ៍**

គឺជាដំណាក់កាលរៀបចំ ឬដំណាក់កាលនៃការធ្វើផែនការ អ្នកប្រតិបត្តិត្រូវអនុវត្តតាមជំហាន ដូចខាងក្រោម៖

**ជំហានទី ១៖ គោលបំណងច្បាស់លាស់**

អ្នកប្រតិបត្តិ ត្រូវយល់ឱ្យច្បាស់អំពីមូលហេតុដែលត្រូវឱ្យកុមារចូលរួម ឬមូលហេតុដែលមិនត្រូវឱ្យកុមារចូលរួមនៅក្នុងព្រឹត្តិការណ៍ដូចជា កិច្ចប្រជុំធ្វើផែនការឃុំ/សង្កាត់ កិច្ចប្រជុំស្តីពីការគ្រប់គ្រងសាលារៀនសិក្ខាសាលាថ្នាក់ជាតិឬថ្នាក់អន្តរជាតិស្តីពីការធ្វើផែនការ ការរៀបចំច្បាប់ និងគោលនយោបាយជាដើម។ ត្រូវដឹងថាព្រឹត្តិការណ៍នោះពាក់ព័ន្ធជាមួយកុមារឬទេ? ប្រសិនបើមិនពាក់ព័ន្ធគឺមិនត្រូវឱ្យកុមារចូលរួមទេ។ តើយើងចង់ឱ្យកុមារធ្វើអ្វីខ្លះ? តើយើងចង់ទទួលបានអ្វីខ្លះពីការចូលរួមរបស់កុមារ? តើនឹងមានហានិភ័យអ្វីខ្លះកើតឡើងចំពោះកុមារនៅពេលដែលកុមារចូលរួម?

**ជំហានទី ២៖ ការចែករំលែកព័ត៌មាន**

នៅក្នុងករណីដែលព្រឹត្តិការណ៍នោះ មានការពាក់ព័ន្ធជាមួយកុមារ អ្នកប្រតិបត្តិគួរចែករំលែកនូវព័ត៌មានអំពីព្រឹត្តិការណ៍នោះជាមួយកុមារ ឬក្រុមកុមារជាមុនដើម្បីឱ្យពួកគេធ្វើការពិចារណា និងត្រៀមខ្លួនសម្រាប់ចូលរួម។ ព័ត៌មានទាំងនោះ គួរតែជាព័ត៌មានលម្អិតគ្រប់គ្រាន់សម្រាប់កុមារក្នុងការធ្វើសេចក្តីសម្រេចចិត្តឱ្យបានត្រឹមត្រូវ។ សំណួរគន្លឹះមានដូចជាតើការពិភាក្សាមានគោលបំណង និងប្រធានបទអ្វីខ្លះ? តើព្រិត្តិការណ៍នេះទាក់ទងនឹងសិទ្ធិកុមារ ឬបញ្ហាដែលពាក់ព័ន្ធជាមួយកុមារឬទេ? តើព្រឹត្តិការណ៍នោះមានដំណើរការយ៉ាងដូចម្តេច? តើលទ្ធផលនៃព្រឹត្តិការណ៍នោះនឹងផ្តល់ផលប្រយោជន៍អ្វីខ្លះដល់កុមារ?

**ជំហានទី ៣៖ ការជ្រើសរើសតំណាងកុមារ**

នៅក្នុងការជ្រើសរើសតំណាងកុមារសម្រាប់ចូលរួមនៅក្នុងព្រឹត្តិការណ៍ អ្នកប្រតិបត្តិគួរតែពិចារណានូវកត្តាដូចខាងក្រោម៖

**ការចូលរួមដោយស្ម័គ្រចិត្ត៖** ត្រូវប្រាកដថា កុមារស្ម័គ្រចិត្តយ៉ាងពេញលេញចូលរួមនៅក្នុងព្រឹត្តិការណ៍ ដោយមានការព្រមព្រៀងបន្ទាប់ពីបានពន្យល់រួចរាល់ ដែលការចូលរួមរបស់ពួកគេមិនមានការបង្ខិតបង្ខំឡើយ។

**ភាពជាតំណាងដ៏ល្អ៖** ភាពជាតំណាងដ៏ល្អនៅក្នុងន័យនេះ គឺសំដៅលើតំណាងមកពីក្រុមផ្សេងៗរបស់កុមារមានកុមារា ឬកុមារី។ ប្រសិនបើអាចធ្វើទៅបានការជ្រើសរើសតំណាងរបស់កុមារគួរធ្វើការជ្រើសរើសយកកុមារពីក្រុមកុមារផ្សេងៗដូចជា កុមារកំពុងសិក្សា កុមារក្រៅសាលា កុមារធ្វើការ កុមារពិការ កុមារមានផ្ទុកមេរោគអេដស៍ កុមារនៃក្រុមជនជាតិភាគតិចកុមារអនាថា កុមាររស់នៅក្នុងមណ្ឌលថែទាំ និងមណ្ឌលកែប្រែ។ល។

**ជំហានទី ៤៖ ទីកន្លែង**

អ្នកប្រតិបត្តិត្រូវបាក្រដថា ព្រឹត្តិការណ៍នោះនឹងត្រូវបានរៀបចំនៅក្នុងទីកន្លែងមួយដែលមានសុវត្ថិភាព និងមានលក្ខណៈមិត្តភាពសម្រាប់កុមារ។ ឧទាហរណ៍ ទីកន្លែងមិនគួរនៅក្បែរផ្លូវ ឬនៅក្រោមអគារចាស់ៗដែលអាចបង្កគ្រោះថ្នាក់ដល់កុមារ។ ទីកន្លែងគួរតែអំណោយផលដល់កុមារពិការហើយបើអាចធ្វើទៅបានទីកន្លែងនោះ គួររៀបចំឱ្យមានការរក្សាភាពជាឯកជនសម្រាប់កុមារី និងកុមារាក្នុងការសម្តែងទស្សនៈរបស់ពួកគេដោយសេរីមិនមានការរំខានអ្វីទាំងអស់។

## ជំហានទី ៥៖ ភាសា និងលំហូរនៃការពិភាក្សា

អ្នកប្រតិបត្តិត្រូវពិចារណាអំពីភាសាដែលប្រើប្រាស់នៅក្នុងព្រឹត្តិការណ៍/សិក្ខាសាលានោះ។ ត្រូវប្រើប្រាស់ភាសា ឬពាក្យពេចន៍ដើម្បីឱ្យកុមារងាយយល់ និងចាប់បាននូវការពិភាក្សានៅពេលដែលពួកគេចូលរួម។ លំហូរនៃការពិភាក្សា គួររៀបចំតាមវិធីមួយដែលមិនមានអារម្មណ៍ភ័យខ្លាច និងមានផាសុកភាពក្នុងការចូលរួមសម្តែងមតិរបស់ពួកគេ។

ក្នុងករណីការពិភាក្សាមិនមែនជាភាសាខ្មែរ អ្នកប្រតិបត្តិគួររៀបចំអ្នកបកប្រែភាសាសម្រាប់កុមារ។

## ជំហានទី ៦៖ ក្រុមគាំទ្រលើកទឹកចិត្ត

ដើម្បីសម្របសម្រួលការចូលរួមរបស់កុមារឱ្យបានរលូននៅក្នុងព្រឹត្តិការណ៍ អ្នកប្រតិបត្តិ គួរពិចារណាបង្កើតនូវក្រុមគាំទ្រលើកទឹកចិត្តមួយសម្រាប់កុមារ ហើយក្រុមគាំទ្រនេះត្រូវត្រៀម ដើម្បីជួយដល់កុមារគ្រប់ពេលវេលាដើម្បីឱ្យកុមារអាចរៀបចំខ្លួន និងត្រៀមខ្លួនចូលរួមនៅក្នុងព្រឹត្តិការណ៍ ឬសកម្មភាពនោះដោយជាក់ស្តែង។

ក្នុងករណីការប្រមូលផ្តុំកុមារទៅក្រៅពីទីតាំងរបស់ពួកគេជំហានទី៧ ទី៨ ទី៩ និងទី១០ គួរត្រូវបានអនុវត្តតាម។

## ជំហានទី ៧៖ ការយល់ព្រម និងការវាយតម្លៃហានិភ័យ

ក្នុងករណីដែលកុមារត្រូវធ្វើដំណើរចេញពីទីតាំងរបស់ពួកគេដើម្បីចូលរួមនៅក្នុងព្រឹត្តិការណ៍ អ្នកប្រតិបត្តិត្រូវសុំការយល់ព្រមពីកុមារ ឪពុកម្តាយ ឬអ្នកអាណាព្យាបាលរបស់កុមារជាលាយលក្ខណ៍អក្សរ និងត្រូវពិភាក្សាអំពីបញ្ហាហានិភ័យ និងវិធីកាត់បន្ថយហានិភ័យចំពោះកុមារ ដើម្បីទប់ស្កាត់ហានិភ័យណាមួយដែលអាចកើតឡើង។

*(សូមអានទម្រង់នៃការយល់ព្រមនៅក្នុងឧបសម្ព័ន្ធទី១ ទី២ និងទី៣)*

**ជំហានទី ៨៖ ការធ្វើដំណើរ និងការស្នាក់នៅ**

ក្នុងករណីដែលកុមារត្រូវធ្វើដំណើរចេញពីទីតាំងរបស់ពួកគេ អ្នកប្រតិបត្តិត្រូវពិចារណា អំពីសុវត្ថិភាពរបស់កុមារពេលធ្វើដំណើរ។ ត្រូវធ្វើការជ្រើសរើសយកមធ្យោបាយដឹកជញ្ជូនកុមារ ដែលគួរឱ្យទុកចិត្ត។

សណ្ឋាគារ ឬផ្ទះសំណាក់ត្រូវធ្វើការជ្រើសរើសដោយប្រយ័ត្នប្រយែងសម្រាប់ការស្នាក់នៅ របស់កុមារ ដើម្បីធានាសុវត្ថិភាពដល់ពួកគេ។ មិនត្រូវឱ្យកុមារស្នាក់នៅកន្លែងដែលមានការប្រើប្រាស់ថ្នាំញៀន ការជួញដូរ និងការកេងប្រវ័ញ្ចផ្លូវភេទ។ល។ ក្រមសីលធម៌ ឬច្បាប់ស្ដីពីកិច្ចការការពារកុមារត្រូវតែអនុវត្ត។

**ជំហានទី ៩៖ អ្នកមើលថែទាំកុមារ**

ក្នុងករណីដែលកុមារត្រូវធ្វើដំណើរចេញពីមូលដ្ឋានរបស់ពួកគេ អ្នកប្រតិបត្តិត្រូវជ្រើសរើសអ្នកមើលថែទាំពួកគ ដើម្បីធ្វើឱ្យកុមារមានភាពកក់ក្ដៅ និងទំនុកចិត្ត។ ការជ្រើសរើសអ្នកមើលថែទាំកុមារត្រូវគិតគូរសំខាន់អំពីភេទ និងអាយុ។ អ្នកមើលថែកុមារម្នាក់គួរថែទាំកុមារត្រឹមតែ ២ ឬ ៣នាក់ ដើម្បីពង្រឹងការមើលថែទាំឱ្យបានហ្មត់ចត់។

*(សូមអានតួនាទីរបស់អ្នកមើលថែទាំកុមារដែលបានស្នើឡើងក្នុងឧបសម្ព័ន្ធទី៣)*

**ជំហានទី ១០៖ ការស្លៀកសម្លៀកបំពាក់សមស្រប**

ក្នុងករណីដែលមានសិក្ខាសាលាថ្នាក់ជាតិ ឬតំបន់អ្នកប្រតិបត្តិត្រូវប្រាកដថា កុមារមានសម្លៀកបំពាក់សមរម្យ ត្រូវពិចារណាអំពីសម្លៀកបំពាក់ប្រពៃណីសម្រាប់ព្រឹត្តិការណ៍តំបន់ និងអន្តរជាតិសម្រាប់ឱ្យកុមារយកទៅតាមខ្លួន។

ក្នុងករណីកុមារក្រីក្រដែលគ្មានលទ្ធភាព អ្នកប្រតិបត្តិត្រូវរៀបចំសម្លៀកបំពាក់ទាំងនោះសម្រាប់កុមារ។

## ដំណាក់កាលក្នុងអំឡុងព្រឹត្តិការណ៍

នេះគឺជាដំណាក់កាលដ៏សំខាន់ ដែលកុមារបញ្ចេញនូវទស្សនៈ កង្វល់ ឬយោបល់របស់ខ្លួន លើបញ្ហាដែលប៉ះពាល់មកលើពួកគេ។ ដូច្នេះ អ្នកប្រតិបត្តិត្រូវសម្របសម្រួលសកម្មភាពនៃការពិភាក្សានៅក្នុងវិធីសាស្ត្រមួយ ដែលធ្វើឱ្យកុមារា និងកុមារីមានភាពក្លាហានអាចបញ្ចេញនូវទស្សនៈរបស់ខ្លួនដោយសេរី និងប្រកបដោយទំនុកចិត្ត។

ការសម្របសម្រួលដើម្បីឱ្យកុមារបានបញ្ចេញនូវទស្សនៈដោយសេរី នៅក្នុងអំឡុងពេលមាន ការពិភាក្សាត្រូវធ្វើឡើងតាមជំហានបន្តបន្ទាប់ដូចខាងក្រោម៖

### ជំហានទី ១៖ ការរៀបចំកន្លែងអង្គុយ

អ្នកប្រតិបត្តិត្រូវរៀបចំបន្ទប់ប្រជុំ ឬទីកន្លែងប្រជុំ ដើម្បីកុំឱ្យកុមារមានអារម្មណ៍ភិតភ័យ ឬមានអារម្មណ៍ថាខ្លួនអន់។ ឧទាហរណ៍ កុមារអាចចង់អង្គុយជាមួយកុមារគ្នាឯងជាជាងអង្គុយជាមួយ មនុស្សធំ។ ប្រសិនបើអាច សូមសាកសួរកុមារថាពួកគេចង់អង្គុយរបៀបយ៉ាងម៉េច។

### ជំហានទី ២៖ ការសម្របសម្រួលការពិភាក្សា

អ្នកប្រតិបត្តិគួររៀបចំការពិភាក្សាក្នុងលក្ខណៈមួយដែលកុមារមិនមានអារម្មណ៍ភិតភ័យតែមានអារម្មណ៍ថាមានផាសុកភាព និងមានទំនុកចិត្តក្នុងការបញ្ចេញនូវទស្សនៈរបស់ខ្លួន។ ប្រសិនបើអាចធ្វើទៅបានសូមព្យាយាមបង្កើតសកម្មភាពសប្បាយៗដល់កុមារ។ ឧទាហរណ៍ ផ្តល់ឱកាសឱ្យកុមារធ្វើការពិភាក្សាក្នុងចំណោមកុមារគ្នាឯង ហើយឡើងរាយការណ៍មកក្រុមធំវិញ ឬក្នុងករណីខ្លះប្រសិនបើកុមារមានការភិតភ័យមិនហ៊ាននិយាយត្រូវប្រាប់ឱ្យកុមារបញ្ចេញគំនិតរបស់ខ្លួន តាមរយៈការសរសេរនៅលើក្រដាស ឬលើប័ណ្ណក្រដាស រួចហើយអ្នកសម្របសម្រួលអាចអានគំនិត ដែលកុមារបានសរសេរនៅលើប័ណ្ណទាំងនោះ។ កុមារអាចចូលរួមពិភាក្សាកាន់តែច្រើនប្រសិន

បើពួកគេស្ថិតនៅក្នុងក្រុមកុមារដែលមានភេទ អាយុ ឬប្រវត្តិដូចៗគ្នា (ឧ. កុមារីដែលធ្វើការមិនបានចូលរៀននៅសាលាអាចធ្វើការពិភាក្សាបានកាន់តែច្រើនប្រសិនបើពួកគេនៅជាមួយកុមារីដទៃទៀតដែលមានប្រវត្តិដូចគ្នា)។

តាមភាពចាំបាច់ អ្នកសម្របសម្រួលគួរប្រើប្រាស់វិធីសាស្ត្រដែលមានការចូលរួម និងមានភាពច្នៃប្រឌិតដើម្បីលើកទឹកចិត្តឱ្យកុមារី និងកុមារាដែលមានអាយុ និងប្រវត្តិខុសៗគ្នាចូលរួមយ៉ាងសកម្ម។ ឧបករណ៍សម្រាប់ការចូលរួមមានដូចជា ផ្ទាំងរូបភាព ផ្ទាំងគំនូរ ឬវិធីសាស្ត្រច្នៃប្រឌិត ផ្សេងៗទៀតអាចរួមចំណែកក្នុងការជំរុញការចូលរួមរបស់កុមារ។

## ជំហានទី ៣៖ ឱកាសស្មើគ្នា

នៅក្នុងពេលពិភាក្សា អ្នកប្រតិបត្តិត្រូវប្រាកដថា អ្នកចូលរួមជាកុមារទាំងអស់ត្រូវមានឱកាស ស្មើគ្នាក្នុងការសម្តែងនូវគំនិត ឬទស្សនៈរបស់ខ្លួនទៅលើបញ្ហាធំៗដូចគ្នានឹងមនុស្សពេញវ័យដែរ។ ត្រូវធានាឱ្យមានឱកាសចូលរួមផងដែរចំពោះកុមារដែលគេមិនសូវយកចិត្តទុកដាក់បំផុត រួមទាំងកុមារពិការ កុមារមកពីគ្រួសារក្រីក្របំផុត។ល។ ដើម្បីឱ្យពួកគេបានបញ្ចេញនូវទស្សនៈបទពិសោធន៍ និងលើកជាសំណើផ្សេងៗ។

## ជំហានទី ៤៖ ការផ្តល់យោបល់ជាវិជ្ជមានត្រឡប់ទៅវិញ

អ្នកប្រតិបត្តិត្រូវលើកទឹកចិត្តកុមារឱ្យចូលរួមពិភាក្សាឱ្យបានច្រើនតាមដែលអាចធ្វើទៅបានត្រូវយកចិត្តទុកដាក់ និងកោតសរសើរដល់ពួកគេ ដោយផ្តល់នូវយោបល់ជាវិជ្ជមានត្រឡប់ទោះបី គំនិតរបស់ពួកគេមិនល្អអស្ចារ្យក៏ដោយ។ការផ្តល់យោបល់ជាវិជ្ជមានត្រឡប់នឹងលើកទឹកចិត្តឱ្យកុមារបញ្ចេញនូវទស្សនៈរបស់ខ្លួនកាន់តែច្រើនឡើង ព្រមទាំងកសាងនូវទំនុកចិត្តរបស់កុមារទៀតផង។ អ្នកប្រតិបត្តិ ឬអ្នកសម្របសម្រួលត្រូវធ្វើការពន្យល់ឱ្យបានច្បាស់លាស់ រួមទាំងការលើកទឹកចិត្តនៅពេលដែលគំនិតរបស់កុមារដែលបានលើកមកនោះមិនសមស្របក្នុងបរិបទខ្លះក៏ដោយ។

**ជំហានទី ៥៖ ការគោរពគ្នាទៅវិញទៅមក**

អ្នកប្រតិបត្តិត្រូវបង្កើតនូវបរិយាកាសឱ្យមានការគោរពគ្នាទៅវិញទៅមកនៅ ក្នុងការពិភាក្សាតាមរយៈការបង្កើតនូវវិធានផ្ទៃក្នុងសម្រាប់អនុវត្ត។ ឧទាហរណ៍ ត្រូវគោរពទស្សនៈរបស់អ្នកចូលរួម រួមទាំងកុមារផងដែរ មិនត្រូវលេងសើច ឬបន្តុះបង្អាប់អ្នកនិយាយទេ។ល។

**ជំហានទី ៦៖ ភាសា**

អ្នកប្រតិបត្តិ ឬអ្នកសម្របសម្រួលត្រូវធ្វើឱ្យប្រាកដថា អ្នកចូលរួមទាំងអស់ ឬវាគ្មិនទាំងអស់ នឹងប្រើប្រាស់នូវភាសាសាមញ្ញសម្រាប់ធ្វើឱ្យកុមារយល់ ឬប្រើប្រាស់រូបភាព ឬផ្ទាំងគំនូរសម្រាប់កុមារ វ័យក្មេង ហើយត្រូវចៀសវាងការប្រើពាក្យបច្ចេកទេស ឬពាក្យគ្រាមភាសា។

**ជំហានទី ៧៖ ការគាំទ្រ**

ដូចដែលបានគ្រោងទុកនៅក្នុងដំណាក់កាលមុនព្រឹត្តិការណ៍ក្រុមគាំទ្រលើកទឹកចិត្តគួរមានវត្តមានដើម្បីជួយដល់កុមារ នៅពេលមានការពិភាក្សាក្នុងករណីកុមារត្រូវការជំនួយណាមួយ។

ក្នុងករណីដែលមានការដឹកជញ្ជូនកុមារចេញពីសហគមន៍ ត្រូវធានាថាកុមារ និងឪពុកម្តាយ ឬអ្នកអាណាព្យាបាលរបស់កុមារអាចទំនាក់ទំនងគ្នាបាននៅពេលមានបញ្ហាបន្ទាន់។

**ដំណាក់កាលក្រោយព្រឹត្តិការណ៍**

នៅក្នុងដំណាក់កាលក្រោយព្រឹត្តិការណ៍ ឬក្រោយពីសកម្មភាពបានបញ្ចប់ អ្នកប្រតិបត្តិគួរផ្តោតលើ ៣ ចំណុចសំខាន់ៗដូចខាងក្រោម៖

១. ត្រូវធានាថា ឪពុកម្តាយ ឬអ្នកអាណាព្យាបាលរបស់កុមារទទួលដំណឹងអំពីការវិលត្រឡប់មកវិញ នៃកូនរបស់ពួកគាត់ដោយសុវត្ថិភាព។

២. សកម្មភាពតាមដានបន្ត៖ ក្នុងករណីធ្វើការតាមដានបន្តអ្នកប្រតិបត្តិ

គួរលើកទឹកចិត្ត ឱ្យកុមារធ្វើការពិភាក្សាក្នុងចំណោមកុមារគ្នាឯង ដូចជាការចែករំលែកនូវលទ្ធផលដែលបានចូលរួមក្នុងព្រឹត្តិការណ៍ដល់មិត្តភក្តិរបស់ខ្លួន ឬលើកទឹកចិត្តឱ្យមានការពិភាក្សាច្រើនថែមទៀតជាមួយកុមារគ្នាឯងអំពីបញ្ហាធំៗជាដើម។

៣. ត្រូវធានាឱ្យមានគណនេយ្យភាពចំពោះកុមារ៖ ត្រូវផ្តល់យោបល់ត្រឡប់ និងប្រាប់កុមារ ដែលបានចូលរួមអំពីលទ្ធផលនៃការពិភាក្សា (ប្រសិនបើលទ្ធផលបានទទួលក្រោយពីចប់ការពិភាក្សា)។

## ការរៀបចំបញ្ជីសម្រាប់ផ្ទៀងផ្ទាត់

- តើកុមារបានទទួលព័ត៌មានពេញលេញអំពីព្រឹត្តិការណ៍ដែរឬទេ?
- តើយើងមានតំណាងកុមារមកពីក្រុមផ្សេងៗដែរឬទេ?
- តើយើងមានក្រុមសម្រាប់គាំទ្រលើកទឹកចិត្តកុមារដែរឬទេ?
- តើយើងបានរៀបចំបរិយាកាសប្រកបដោយភាពស្និទ្ធស្នាលសម្រាប់កុមារនៅក្នុងព្រឹត្តិការណ៍ដែរឬទេ?
- តើយើងបានលើកទឹកចិត្តកុមារឱ្យរៀបចំផែនការតាមដានបន្តបន្ទាប់ពីព្រឹត្តិការណ៍ដែរឬទេ?
- តើយើងបានគិតអំពីការធ្វើដំណើរនិងការស្នាក់នៅរបស់កុមារប្រកបដោយសុវត្ថិភាព ដែរឬទេ?
- តើយើងបានឱ្យកុមារចុះហត្ថលេខាលើទម្រង់នៃការព្រមព្រៀងដែរឬនៅ?
- តើកុមារបានប្រគល់ទម្រង់នៃការវាយតម្លៃអំពីហានិភ័យដែរឬទេ?
- តើឪពុកម្តាយរបស់កុមារបានចុះហត្ថលេខាលើទម្រង់នៃការព្រមព្រៀងដែរឬទេ?
- តើអ្នកមើលថែកុមារបានចុះហត្ថលេខាលើទម្រង់នៃការព្រមព្រៀងដែរឬទេ?
- តើយើងបានរៀបចំសម្លៀកបំពាក់សមស្របសម្រាប់កុមារដែរឬទេ?

**ប្រការ ៧.-**

បទប្បញ្ញត្តិទាំងឡាយណាដែលផ្ទុយពីសេចក្តីសម្រេចនេះ ត្រូវទុកជានិរាករណ៍។

**ប្រការ ៨.-**

ក្រសួង ស្ថាប័ន ដែលជាសមាជិកក្រុមប្រឹក្សាជាតិកម្ពុជាដើម្បីកុមារ ក្រុមប្រឹក្សាជាតិកម្ពុជាដើម្បីកុមារថ្នាក់រាជធានី ខេត្ត ក្រុមការងារដើម្បីកុមារតាមក្រសួង ស្ថាប័ន អង្គការមិនមែនរដ្ឋាភិបាលជាតិ អន្តរជាតិ ដែលពាក់ព័ន្ធនឹងការងារកុមារទាំងអស់ មានភារកិច្ចអនុវត្តសេចក្តីសម្រេចនេះឱ្យមានប្រសិទ្ធភាពចាប់ពីថ្ងៃចុះហត្ថលេខាតទៅ។

**ប្រធានក្រុមប្រឹក្សាជាតិកម្ពុជាដើម្បីកុមារ**

**វង សូត**

**ចម្លងជូន៖**

- ក្រសួងព្រះបរមរាជវាំង
- អគ្គលេខាធិការដ្ឋានក្រុមប្រឹក្សាធម្មនុញ្ញ
- អគ្គលេខាធិការដ្ឋានព្រឹទ្ធសភា
- អគ្គលេខាធិការដ្ឋានរដ្ឋសភា
- អគ្គលេខាធិការរាជរដ្ឋាភិបាល
- ខុទ្ទកាល័យសម្តេចតេជោនាយករដ្ឋមន្ត្រី
- ខុទ្ទកាល័យឯកឧត្តមឧបនាយករដ្ឋមន្ត្រីប្រចាំការ
- ដូចប្រការ ៨
- រាជកិច្ច
- ឯកសារ-កាលប្បវត្តិ

## ឧបសម្ព័ន្ធ ១៖ ទម្រង់នៃការព្រមព្រៀងសម្រាប់កុមារ

ខ្ញុំបាទ/នាងខ្ញុំឈ្មោះ (ឈ្មោះរបស់កុមារ).....................រស់នៅក្នុង............. ...................(អាសយដ្ឋានរបស់កុមារ) បន្ទាប់ពីបានស្តាប់ការពន្យល់ដោយ (បុគ្គលិកអ្នករៀបចំកម្មវិធី/ជនបង្គោល)........................អំពីគោលបំណង និងដំណើរការនៃព្រឹត្តិការណ៍...........................ខ្ញុំ(ឈ្មោះកុមារ)................ បានព្រមព្រៀងចូលរួមនៅក្នុង (ឈ្មោះព្រឹត្តិការណ៍ /សកម្មភាព) .............. ..........ដែលរៀបចំដោយ (ឈ្មោះទីភ្នាក់ងាររៀបចំកម្មវិធី)......................... ...........នៅឯ(ទីកន្លែង)..................................... ពីថ្ងៃទី (កាលបរិច្ឆេទនៃសិក្ខាសាលា/ព្រឹត្តិការណ៍)...........................ដែលមានកាលបរិច្ឆេទចេញដំណើរនៅថ្ងៃទី......................និងកាលបរិច្ឆេទមកដល់ថ្ងៃទី..................... គោលបំណងនៃការចូលរួមរបស់ខ្ញុំនៅក្នុងព្រឹត្តិការណ៍/សកម្មភាពនោះគឺដើម្បី ..................................................ការចូលរួមរបស់ខ្ញុំស្ថិតនៅក្រោមការមើលថែទាំ និងគាំទ្រដោយ (ឈ្មោះរបស់អ្នកមើលថែទាំកុមារ/ឈ្មោះរបស់បុគ្គលិកនៃទីភ្នាក់ងារដែលរៀបចំកម្មវិធី ឧ. បុគ្គលិកអង្គការមិនមែនរដ្ឋាភិបាល /បុគ្គលិកឃុំ) ........................ ...............រាល់ការចំណាយក្នុងការស្នាក់នៅចំណីអាហារ និងផ្សេងៗទៀតត្រូវបានទូទាត់ ដោយ (ឈ្មោះរបស់ទីភ្នាក់ងារ) ................................ខ្ញុំបានដឹងអំពីហានិភ័យដែលអាចកើតឡើងនៅក្នុងការធ្វើដំណើរ និងនៅក្នុងព្រឹត្តិការណ៍/សកម្មភាពនោះ។ ក្នុងករណីបន្ទាន់ឪពុកម្តាយរបស់ខ្ញុំអាចធ្វើទំនាក់ទំនងមកខ្ញុំតាមលេខ (លេខទំនាក់ទំនងអ្នករៀបចំកម្មវិធី)........................។

| ហត្ថលេខាកុមារ | ឈ្មោះកុមារ (សរសេរ) | កាលបរិច្ឆេទ |
|---|---|---|

## ឧបសម្ព័ន្ធទី ២៖ ទម្រង់នៃការវាយតម្លៃ និងការកាត់បន្ថយហានិភ័យ

ទម្រង់នេះសម្រាប់កុមារគិត និងពិភាក្សាជាមួយឪពុកម្ដាយ ឬអ្នកអាណាព្យាបាលរបស់ពួកគេអំពីហានិភ័យ ដែលអាចកើតឡើងចំពោះពួកគេនៅក្នុងពេលធ្វើដំណើរទៅចូលរួមនៅក្នុងព្រឹត្តិការណ៍ ឬសកម្មភាពនានា។

តំណាងមនុស្សពេញវ័យ អញ្ជើញពួកគេ ឬឪពុក ឬម្ដាយ ឬអ្នកមើលថែទាំកុមារអាចជួយកុមារក្នុងការកំណត់នូវហានិភ័យនេះ ប្រសិនបើពួកគេត្រូវការជំនួយ។

ទម្រង់នេះត្រូវភ្ជាប់ជាមួយទម្រង់នៃការព្រមព្រៀងសម្រាប់កុមារ ដែលពួកគេអាចផ្ញើរួមគ្នាទៅអ្នករៀបចំកម្មវិធី។

| **ហានិភ័យ**<br>ចូរកំណត់ថាតើមានហានិភ័យអ្វីខ្លះដែលអ្នករំពឹងថាអាចនឹងកើតមានឡើង និងអាចធ្វើឱ្យប៉ះពាល់អ្នកនៅពេលដែលអ្នកចូលរួមនៅក្នុងព្រឹត្តិការណ៍នោះ | **វិធីកាត់បន្ថយហានិភ័យ**<br>យោងតាមគំនិតនិងបទពិសោធន៍របស់អ្នកតើអ្នកនឹងកាត់បន្ថយហានិភ័យដែលអាចកើតមានឡើងយ៉ាងដូចម្ដេច? | **អ្នកណាខ្លះអាចជួយបាន**<br>នៅពេលដែលអ្នកកំពុងធ្វើដំណើរដោយមានហេតុការណ៍អ្វីមួយកើតឡើង ឬកំពុងចូលរួមនៅក្នុងព្រឹត្តិការណ៍មួយស្រាប់តែមានអ្វីមួយកើតឡើងនៅពេលដែលអ្នកប្រឈមនឹងហានិភ័យ និងចង់កាត់បន្ថយវា តើអ្នកណាខ្លះដែលអ្នកនឹងសុំជំនួយ? |
|---|---|---|
| | | |
| | | |

ហត្ថលេខារបស់កុមារ ឈ្មោះរបស់កុមារ (សរសេរ) កាលបរិច្ឆេទ

## ឧបសម្ព័ន្ធទី ៣៖ ទម្រង់នៃការព្រមព្រៀងរបស់ឪពុកម្តាយ

ខ្ញុំបាទឬនាងខ្ញុំឈ្មោះ............... (ឈ្មោះរបស់ឪពុក ឬម្តាយ) ត្រូវជាឪពុក ឬម្តាយរបស់កុមារឈ្មោះ ................ (ឈ្មោះរបស់កុមារ) រស់នៅ............... .................. (អាស័យដ្ឋានរបស់ឪពុកម្តាយ...) បានយល់ព្រម និងអនុញ្ញាតិឲ្យកូនរបស់ខ្ញុំចូលរួមនៅក្នុងសិក្ខាសាលា ឬព្រឹត្តិការណ៍ឬសកម្មភាព............ ........................... ដែលរៀបចំដោយ................. (ឈ្មោះរបស់ទីភ្នាក់ងារដែលរៀបចំកម្មវិធី.....) នៅឯ................. (ទីកន្លែង) .........ពីថ្ងៃទី................. (កាលបរិច្ឆេទនៃសិក្ខាសាលា/ព្រឹត្តិការណ៍...) កាលបរិច្ឆេទចាកចេញថ្ងៃទី ...........................និងកាលបរិច្ឆេទត្រឡប់មកវិញ ថ្ងៃទី ........................... គោលបំណងនៃការចូលរួមរបស់កូនរបស់ខ្ញុំនៅក្នុងព្រឹត្តិការណ៍/សកម្មភាពនោះគឺដើម្បី.................... បន្ទាប់ពីបានស្តាប់ការពន្យល់ពី ........................... (បុគ្គលិករៀបចំកម្មវិធី/ជនបង្គោល...) ខ្ញុំបានព្រមព្រៀង អនុញ្ញាតិឲ្យកូនរបស់ខ្ញុំធ្វើដំណើរជាមួយ និងស្ថិតនៅក្រោមការថែទាំ និងគាំទ្រពី ................. (ឈ្មោះ អ្នកថែទាំកុមារ ឬបុគ្គលិកនៃទីភ្នាក់ងារដែលរៀបចំកម្មវិធី ឧ.អង្គការមិនមែនរដ្ឋាភិបាល/បុគ្គលិកឃុំ) .................................រាល់ការចំណាយទាំងអស់លើការធ្វើដំណើរការស្នាក់នៅ និងចំណីអាហារ និងអ្វីផ្សេងៗទៀតត្រូវបានរ៉ាប់រងដោយ..........................................(ឈ្មោះរបស់ទីភ្នាក់ងារ) ខ្ញុំបានដឹងអំពីហានិភ័យដែលអាចកើតឡើងនៅក្នុងការធ្វើដំណើរ និងនៅក្នុងព្រឹត្តិការណ៍/សកម្មភាពនោះ។

ក្នុងករណីបន្ទាន់ខ្ញុំអាចធ្វើការទំនាក់ទំនងជាមួយអង្គការតាមលេខ...................... ហើយបើមានបញ្ហាអ្វីអាចទាក់ទងមកខ្ញុំតាមលេខ.......................................

| ___________________ | ___________________ | ___________________ |
|---|---|---|
| ហត្ថលេខា ឬស្នាមដៃរបស់ឪពុក/ម្តាយ | ឈ្មោះឪពុក/ម្តាយ (សរសេរ) | កាលបរិច្ឆេទ |

## ឧបសម្ព័ន្ធទី៤៖ ទម្រង់នៃការព្រមព្រៀងរបស់អ្នកមើលថែទាំកុមារ

ខ្ញុំបាទឬនាងខ្ញុំឈ្មោះ(ឈ្មោះអ្នកមើលថែទាំកុមារ).....................ភេទ......... អាយុ...... រស់នៅក្នុង (អាសយដ្ឋានរបស់អ្នកមើលថែ).............................. បានយល់ព្រមមើលថែទាំកុមារ(ឈ្មោះរបស់កុមារ).................នៅក្នុង (ឈ្មោះព្រឹត្តិការណ៍/សកម្មភាព)...................ដែលរៀបចំដោយ (ឈ្មោះរបស់ទីភ្នាក់ងាររៀបចំកម្មវិធី)នៅឯ(ទីកន្លែង)...................ចាប់ពីថ្ងៃទី(កាលបរិច្ឆេទនៃព្រឹត្តិការណ៍ /សកម្មភាព).................កាលបរិច្ឆេទធ្វើដំណើរថ្ងៃទី................ ........និងកាលបរិច្ឆេទត្រឡប់មកវិញ ថ្ងៃទី.......................រាល់ការចំណាយទាំងអស់ក្នុងការធ្វើដំណើរ ការស្នាក់នៅ និងចំណីអាហារ និង ផ្សេងៗទៀតត្រូវបានរ៉ាប់រងដោយ(ឈ្មោះរបស់ទីភ្នាក់ងារ)...................។ ខ្ញុំបានដឹងអំពីហានិភ័យ ដែលអាចកើតឡើងនៅក្នុងពេលធ្វើដំណើរ និងនៅក្នុងព្រឹត្តិការណ៍/សកម្មភាពនេះ។

នៅក្នុងកិច្ចការនេះ ខ្ញុំមានភារកិច្ចត្រូវអនុវត្តតាមវិធានដូចខាងក្រោម៖
ខ្ញុំមិនត្រូវ៖

- វាយ ឬបំពានលើរាងកាយរបស់កុមារដែលខ្ញុំត្រូវមើលថែទាំនោះឡើយ
- មានទំនាក់ទំនងជាមួយកុមារដែលខ្ញុំត្រូវមើលថែទាំទាំងទំនាក់ទំនងរាងកាយ និងផ្លូវភេទ
- ធ្វើសកម្មភាពណាមួយចំពោះកុមារដែលខ្ញុំត្រូវមើលថែទាំដែលត្រូវបានគេមើលឃើញថាមានគោលបំណងជាការកេងប្រវ័ញ្ចឬរំលោភបំពានលើកុមារនោះឡើយ
- ធ្វើសកម្មភាពណាមួយដែលរំលោភបំពានឬបង្កឱ្យកុមារដែលខ្ញុំត្រូវមើលថែទាំ ធ្លាក់ខ្លួនទៅក្នុងសកម្មភាពរំលោភបំពានឡើយ

- ប្រើប្រាស់ភាសា លើកសំណើ ឬផ្តល់យោបល់ដែលមិនសមស្រប ដែលធ្វើឱ្យអាក់អន់ចិត្ត ឬមានលក្ខណៈរំលោភបំពានឡើយ
- ធ្វើកាយវិការដែលមិនសមស្រប ឬដែលជំរុញអារម្មណ៍ផ្លូវភេទឡើយ
- ដេកក្នុងបន្ទប់ ឬគ្រែតែមួយជាមួយកុមារដែលខ្ញុំត្រូវមើលថែទាំឡើយ
- ធ្វើអ្វីមួយដែលមានបំណងធ្វើឱ្យអៀនខ្មាស់បន្តុះបង្អាប់និយាយមើលងាយ ឬបន្ទាបបន្ថោក ចំពោះកុមារដែលខ្ញុំត្រូវមើលថែទាំឬប្រព្រឹត្តទម្រង់ណាមួយដែលធ្វើឱ្យប៉ះពាល់ដល់ផ្លូវចិត្តរបស់កុមារឡើយ
- ធ្វេសប្រហែស ឬអនុញ្ញាតឱ្យកុមារទៅក្រៅ ឬធ្វើសកម្មភាពអ្វីមួយដោយមិនបានឃ្លាំមើលឡើយ។

ខ្ញុំបានអានវិធានស្តីពីការប្រកាន់ឥរិយាបថចំពោះកុមារនេះហើយ ខ្ញុំបានយល់អំពីខ្លឹមសាររបស់វិធាននេះ និងបានយល់ស្របតាមលក្ខខណ្ឌដែលមានចែងនៅក្នុងវិធាននេះផងដែរ។

| ______________________ | ______________________ | ______________________ |
| --- | --- | --- |
| ហត្ថលេខាអ្នកមើលថែទាំកុមារ | ឈ្មោះអ្នកមើលថែទាំកុមារ | កាលបរិច្ឆេទ |

បានទទួលដឹងឮពីមេឃុំ ឬចៅសង្កាត់ ឬប្រធានភូមិ ឬប្រធានស្ថាប័ន

| ______________________ | ______________________ | ______________________ |
| --- | --- | --- |
| ហត្ថលេខា | ឈ្មោះ និងតួនាទី | កាលបរិច្ឆេទ |

## ឧបសម្ព័ន្ធទី ៥៖ មាត្រាដែលពាក់ព័ន្ធនឹងការចូលរួមរបស់កុមារ

## អនុសញ្ញាស្តីពីសិទ្ធិកុមារ

មាត្រា ១២៖

១. រដ្ឋភាគីត្រូវធានាដល់កុមារដែលមានសមត្ថភាពបង្កើតទស្សនៈផ្ទាល់ខ្លួន នូវសិទ្ធិបញ្ចេញទស្សនៈ ទាំងនោះដោយសេរីលើគ្រប់បញ្ហាពាក់ព័ន្ធនឹងកុមារ។ ទស្សនៈទាំងនេះរបស់កុមារត្រូវបានយកទៅពិចារណាថ្លឹងថ្លែងដោយគិតទៅតាមវ័យ និងភាពចាស់ទុំរបស់កុមារ។

២. ក្នុងគោលបំណងនេះ កុមារត្រូវបានផ្តល់ឱកាសពិសេសក្នុងការចូលរួមស្តាប់រាល់សវនការនិងរាល់ដំណើរការរដ្ឋបាលទាក់ទងនឹងកុមារដោយផ្ទាល់ ឬតាមរយៈតំណាង ឬអង្គភាពដែលមាន លក្ខណសម្បត្តិគ្រប់គ្រាន់ដោយអនុលោមទៅតាមនីតិវិធី និងច្បាប់ជាតិជាធរមាន។

មាត្រា ១៣៖ កុមារមានសិទ្ធិសម្តែងមតិដោយសេរី។ សិទ្ធិនេះរាប់បញ្ចូលទាំងសេរីភាពស្រាវជ្រាវទទួលនិងផ្សព្វផ្សាយព័ត៌មាននិងគំនិតគ្រប់ប្រភេទដោយគ្មានគិតពីព្រំដែន ទោះជាតាមទម្រង់ ផ្ទាល់មាត់ សរសេរ ឬបោះពុម្ព ទម្រង់សិល្បៈ ឬតាមគ្រប់ប្រព័ន្ធផ្សព្វផ្សាយព័ត៌មានផ្សេងទៀត តាមការជ្រើសរើសរបស់ ពួកុមារ។

មាត្រាដទៃទៀតមាន៖

មាត្រា ១៤៖ សេរីភាពគិតគូរ សេរីភាពខាងសតិសម្បជញ្ញៈ និងសេរីភាពខាងសាសនា

មាត្រា ១៥៖ សេរីភាពខាងសមាគម

មាត្រា ១៧៖ សិទ្ធិទទួលបានព័ត៌មាន និងប្រព័ន្ធផ្សព្វផ្សាយ

មាត្រា ៣០៖ សិទ្ធិប្រតិបត្តិសកម្មភាពវប្បធម៌

មាត្រា ៣១៖ សិទ្ធិចូលរួមនៅក្នុងជីវភាពវប្បធម៌

## រដ្ឋធម្មនុញ្ញរបស់ប្រទេសកម្ពុជា

មាត្រា ៤១៖ សេរីភាពបញ្ចេញមតិ សេរីភាពខាងសារព័ត៌មាន បោះពុម្ពផ្សាយ និងប្រមូលផ្តុំ

មាត្រា ៤៣៖ សេរីភាពខាងជំនឿ

## ឧបសម្ព័ន្ធទី៦៖ វិធីសាស្ត្រ

គោលការណ៍ណែនាំនេះ ត្រូវបានរៀបរៀងតាមការចង្អុលបង្ហាញពីក្រុមការងារបច្ចេកទេស នៃអគ្គលេខាធិការដ្ឋានក្រុមប្រឹក្សាជាតិកម្ពុជាដើម្បីកុមារ។ ព័ត៌មាននេះត្រូវបានប្រមូលពីប្រភព ៣ ផ្សេងគ្នាគឺ៖ ការសិក្សាស្រាវជ្រាវតាមឯកសារដែលមានស្រាប់ការធ្វើសម្ភាស និងការពិភាក្សាជាក្រុម និងការសង្កេត។

ការសិក្សាស្រាវជ្រាវលើឯកសារដែលមានស្រាប់ គឺជាការសិក្សាឡើងវិញដ៏ស៊ីជម្រៅនូវ គោលការណ៍ណែនាំជាតិ និងអន្តរជាតិ និងឯកសារនានាស្តីពីទ្រឹស្តី និងការអនុវត្តនៃការចូលរួមរបស់កុមារនៅក្នុងប្រទេស ក៏ដូចជានៅក្នុងតំបន់ និងនៅក្នុងបណ្តាប្រទេសផ្សេងៗ ដើម្បីទទួលបាននូវធាតុចូលគំនិត និងការអនុវត្តរួមដើម្បីរៀបចំគោលការណ៍ណែនាំនេះឱ្យស្របគ្នានឹងបរិបទរបស់ប្រទេសកម្ពុជា។

ការសម្ភាស និងការពិភាក្សាជាក្រុមជាមួយអ្នកផ្តល់នូវព័ត៌មានសំខាន់ៗពីក្រុមប្រឹក្សាជាតិកម្ពុជាដើម្បីកុមារ ក្រសួងអប់រំ យុវជន និងកីឡា ក្រសួងមហាផ្ទៃ អង្គការមិនមែនរដ្ឋាភិបាល នាយកសាលា ក្រុមប្រឹក្សាឃុំ កុមារ និងយុវជន ដើម្បីប្រមូលនូវបទពិសោធន៍មេរៀនដែលបានរៀនពីការអនុវត្តល្អៗ ការប្រឈម និងអនុសាសន៍នានា។

ចំពោះការអង្កេតមានការបញ្ចូលនូវបទពិសោធន៍និងជំនាញផ្ទាល់ខ្លួនរបស់ទីប្រឹក្សាអំពីការចូលរួមរបស់កុមារនៅក្នុងគោលការណ៍ណែនាំនេះ។

ជាចុងក្រោយ សេចក្តីព្រាងនៃគោលការណ៍ណែនាំនេះត្រូវបានពិគ្រោះ និងពិនិត្យឡើងវិញដោយអ្នកជំនាញ និងអ្នកមានវិជ្ជាជីវៈខាងសិទ្ធិកុមារ យុវជន និងកុមារ អង្គការសង្គមស៊ីវិល និងទីភ្នាក់ងាររបស់រដ្ឋាភិបាល។

# ឯកសារយោង

១- គោលនយោបាយជាតិស្តីពីការអភិវឌ្ឍយុវជន ក្រសួងអប់រំ យុវជន និងកីឡា ឆ្នាំ២០១១

២- ច្បាប់អង្គការ ក្រសួងមហាផ្ទៃ ឆ្នាំ២០០៨

៣- ប្រកាសលេខ ៤២៧៥ បរក ស្តីពីការរៀបចំ និងការប្រព្រឹត្តទៅនៃគណៈកម្មាធិការពិគ្រោះយោបល់កិច្ចការស្ត្រី និងកុមារ នៅក្រុមប្រឹក្សា រាជធានី ខេត្ត ក្រុង ស្រុក និងខណ្ឌ ឆ្នាំ២០០៩

៤- គោលការណ៍ណែនាំលេខ ១២១២ ស្តីពីការបង្កើតក្លឹបកុមារ និងយុវជន នៅសាលារៀន អនុវិទ្យាល័យ និងវិទ្យាល័យ ក្រសួងអប់រំ យុវជន និងកីឡា ឆ្នាំ២០០៣

៥- គោលការណ៍ណែនាំលេខ ៤០៦ ស្តីពីការលើកកម្ពស់កុមារល្អបីប្រការៈ កូនល្អ សិស្សល្អ ពលរដ្ឋល្អក្រសួងអប់រំ យុវជន និងកីឡា ឆ្នាំ២០០៣

៦- បទដ្ឋានអនុវត្តនៅក្នុងការចូលរួមរបស់កុមារ អង្គការ Save the Children

៧- ការដាក់កុមារនៅមណ្ឌល។ គោលការណ៍ណែនាំជាក់ស្តែងចំពោះការចូលរួមរបស់កុមារអង្គការសម្ព័ន្ធសង្គ្រោះកុមារអន្តរជាតិ ឆ្នាំ២០១០

៨- សៀវភៅណែនាំអនុវត្តអនុសញ្ញាស្តីពីសិទ្ធិកុមារ អង្គការយូនីសេហ្វ ឆ្នាំ២០០២

៩- គោលការណ៍ណែនាំ អំពីការចូលរួមរបស់កុមារនៅថ្នាក់ជាតិសម្រាប់ប្រទេសអ៊ូហ្កង់ដា ឆ្នាំ២០០៨

១០- លក្ខខណ្ឌ ៩យ៉ាងនៃការចូលរួមរបស់កុមារ យោបល់ទូទៅអំពីមាត្រា ១២ ដោយគណៈកម្មាធិការសហប្រជាជាតិស្តីពីសិទ្ធិកុមារ

១១- ការចូលរួមរបស់កុមារនៅក្នុងការធ្វើសេចក្តីសម្រេចៈ ហេតុអ្វីត្រូវឱ្យកុមារ

ចូលរួមនៅពេលណាកុមារត្រូវចូលរួម និងត្រូវចូលរួមយ៉ាងដូចម្ដេច? ក្រុមការងារអន្តរទីភ្នាក់ងារស្ដីពីការចូលរួមរបស់កុមារ (IAWGCP) ឆ្នាំ២០០៧

១២- សៀវភៅណែនាំប្រតិបត្តិស្ដីពីការចូលរួមរបស់កុមារនៅក្នុងការពិគ្រោះយោបល់ក្រុមការងារអន្តរទីភ្នាក់ងារស្ដីពីការចូលរួមរបស់កុមារ (IAW GCP) ឆ្នាំ២០០៧

១៣- ការយកចិត្តទុកដាក់ចំពោះកុមារជាដំបូងសិន គោលការណ៍ណែនាំស្ដីពីការចូលរួមរបស់កុមារ សម្រាប់គម្រោងទប់ស្កាត់ការជួញដូរកុមារនៅក្នុងប្រទេសចិន ខែឧសភា ឆ្នាំ២០០៦

១៤- គោលការណ៍ណែនាំសម្រាប់លើកកម្ពស់ការចូលរួមរបស់កុមារ អង្គការសុខភាពគ្រួសារអន្តរជាតិ

១៥- ត្រពាំងស្នងឬស្សី សៀវភៅណែនាំអំពីការបណ្ដុះបណ្ដាលស្ដីពីការអភិវឌ្ឍសហគមន៍ដោយមានការគិតគូរបំផុតចំពោះកុមារ/សកម្មភាពសហគមន៍ដែលដឹកនាំដោយកុមារ សម្រាប់អ្នកសម្របសម្រួលដែលធ្វើការជាមួយកុមារ និងក្រុមយុវជន ការិយាល័យតំបន់របស់អង្គការភ្លែនអាស៊ី ឆ្នាំ២០១០

១៦- មនុស្សធំមុន! របាយការណ៍នៃការបណ្ដុះបណ្ដាលអំពីការបណ្ដុះបណ្ដាលលើការរៀបចំការចូលរួមរបស់កុមារ អង្គការសង្គ្រោះកុមារ ស៊ុយអែត និងHenk van Beers ឆ្នាំ២០០៦

១៧- ការធានាឱ្យមានការចូលរួមប្រកបដោយអត្ថន័យរបស់កុមារ និងយុវជននៅក្នុងការប្រយុទ្ធប្រឆាំងការធ្វើអាជីវកម្មផ្លូវភេទលើកុមារ៖ បទពិសោធន៍នៃអង្គការអ៊ីកផាត អង្គការអ៊ីកផាតអន្តរជាតិ ឆ្នាំ២០០៧

១៨- ការពិនិត្យតាមដាន និងវាយតម្លៃក្របខ័ណ្ឌនៃការចូលរួមរបស់កុមារដោយ Genrison Lansdown ខែកក្កដា ឆ្នាំ២០១១។